ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២០៨
ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២
សាលដីកា
លេខ ៥៤០ VII
ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.ឯកឧត្តម [redacted] ចៅក្រម

៣.ឯកឧត្តម [redacted] ចៅក្រម

៤.ឯកឧត្តម [redacted] ចៅក្រម

៥.លោកជំទាវ [redacted] ចៅក្រម

### ចៅក្រមរបាយការណ៍

-លោកជំទាវ [redacted]

### ក្រឡាបញ្ជីសវនាការ

-លោក [redacted]

### តំណាងមហាអយ្យការ

-ឯកឧត្តម [redacted] ឋានៈជាព្រះរាជអាជ្ញារង

### ដើម្បីជំនុំជម្រះ

លើបណ្ដឹងសាទុក្ខលេខ ១៧៣៣ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ របស់លោកជំទាវ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល សំណុំរឿងព្រហ្មទណ្ឌលេខ ២០៨ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០២២ របស់តុលាការកំពូលដែលមាន ៖

-ជនជាប់ចោទឈ្មោះ[redacted]គួយ ហៅ ម៉ៅ ភេទប្រុស កើតឆ្នាំ១៩៩៣ ជនជាតិខ្មែរ មុខរបរជាងឈើ ទីកន្លែងកំណើតនៅ ភូមិស្គំ ឃុំក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅមុនពេលឃុំខ្លួននៅភូមិ



Scanned with CamScanner

[redacted]ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន ។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១២៧ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ នៅពន្ធនាគារខេត្តត្បូងឃ្មុំ ។

ជាប់ចោទពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិជើងអង ឃុំកណ្តោលជ្រុំ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

-មានលោ[redacted]បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-លោកជំទាវ អគ្គព្រះរាជអាជ្ញនៃមហាអយ្យការអមតុលាការកំពូល ប្តឹងសាទុក្ខ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ចាន់រ៉ា ភេទស្រី អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ[redacted]កពញាក្រែក ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted]ស) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោ[redacted]មានកូន ០២នាក់ ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១៩: ៣០នាទី ជនរងគ្រោះឈ្មោះ [redacted] ចាន់រ៉ា ភេទស្រី អាយុ ៣៣ឆ្នាំ កំពុងងូតទឹកនៅក្នុងបន្ទប់ក្រោមផ្ទះ ស្ថិតនៅភូមិជើងអង ឃុំកណ្តោលជ្រុំ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ហើយនៅខណៈពេលនោះជនជាប់ចោទឈ្មោះ [redacted]កួយ ហៅ ម៉ៅ ជាអ្នកជិតខាងបានដឹងថា ជនរងគ្រោះកំពុងងូតទឹក ក៏មានអារម្មណ៍ចង់រួមភេទ រួចនៅពេលកំពុងឃើញជនរងគ្រោះកំពុងរៀបដើរចេញពីបន្ទប់ទឹក ជនជាប់ចោទបានកាន់កូនកាំបិតចូលទៅគំរាមជនរងគ្រោះកុំឱ្យមាត់ និងចាប់ដៃជនរងគ្រោះប្រានចូលក្នុងបន្ទប់ទឹក ក្នុងគោលបំណងរំលោភសេពសន្ថវៈ តែជនរងគ្រោះរើបម្រាស់ ដៃជនរងគ្រោះមុតនឹងកូនកាំបិត និងស្រែកហៅឱ្យគេជួយ ទើបធ្វើឱ្យជនជាប់ចោទបញ្ឈប់សកម្មភាព ហើយជនរងគ្រោះក៏បានរត់ចេញពីបន្ទប់ទឹក ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៦២ "ឆ" ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ដែលមានខ្លឹមសារសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសលើឈ្មោ[redacted] កួយ (ហៅ ម៉ៅ) ភេទប្រុស អាយុ ២៨ឆ្នាំ (ដែលមានសាវតារជាតិ) ដាក់ពន្ធនាគារកំណត់ចំនួន ៥ (ប្រាំ)ឆ្នាំ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិជើងអង ឃុំកណ្តោលជ្រុំ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] កួយ (ហៅ ម៉ាប់) និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted] ចាន់រ៉ា ។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។



Scanned with CamScanner

-បានឃើញ បណ្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៤៤៤២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] កួយ ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ២៦២ "ឆ" ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៤៩ ព្រ.ទ ក្រ.IV(រ.ភ) ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៤៤២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] កួយ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦២ "ឆ" ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ទុកជាបានការលើកលែងចំណុច១ នៃសេចក្តីសម្រេចត្រូវកែប្រែ និងសម្រេចជាថ្មីថា៖

-ផ្តន្ទាទោសលើឈ្មោះ [redacted] កួយ ហៅ ម៉ៅ ភេទប្រុស អាយុ ២៨ឆ្នាំ (មានសាវតារជាតិ) ដាក់ពន្ធនាគារកំណត់ចំនួន ០២(ពីរ)ឆ្នាំ ពីបទ៖ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិជើងអង ឃុំកណ្តោលជ្រុំ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃពុធ ០៨កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] កួយ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់រ៉ា ។ ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ១៧៣៣ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ របស់លោកជំទាវ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ប្តឹងមិនសុខចិត្ត នឹងសាលដីកាព្រហ្មទណ្ឌលេខ ៤៩ ព្រ.ទ ក្រ.IV(រ.ភ) ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ត្បូងឃ្មុំ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សារណាការពារ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ របស់លោកជំទាវ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានឡើងធ្វើសេចក្តីរាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋាននិងប្តឹងសុំថា មាត្រា ២៣៩ បានបញ្ញត្តិថា បទ រំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ និងមាត្រា ២៧ បានឱ្យនិយមន័យនៃការប៉ុនប៉ងយ៉ាងច្បាស់លាស់ ។ ដូចនេះ សាលាឧទ្ធរណ៍ត្បូងឃ្មុំ បានសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] កួយ ហៅ ម៉ៅ ដាក់ពន្ធនាគារកំណត់រយៈ ២ឆ្នាំ នោះ គឺពុំត្រឹមត្រូវតាមបញ្ញត្តិនៃមាត្រា ២៣៩ ឡើយ ។ សូមក្រុមប្រឹក្សាជំនុំជម្រះសភាព្រហ្មទណ្ឌតុលាការកំពូលបដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៤៩ ព្រ.ទ ក្រ.IV(រ.ភ) ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ត្បូងឃ្មុំចោល និងបង្វិលទៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីជំនុំជម្រះសារជាថ្មី ។



Scanned with CamScanner

-លោ[redacted]បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]គួយ ហៅ ម៉ៅ បានធ្វើសេចក្ដីសន្និដ្ឋានថា ដោយយោងតាមមាត្រា ៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងអំពីស្ថានសម្រាល គឺចូលក្នុងលក្ខខណ្ឌរបស់កូនក្ដីខ្លួន សំអាងថា កូនក្ដីខ្លួនបានសារភាព ហើយអំពើដែលបានប្រព្រឹត្តមិនទាន់កើតឡើងនៅឡើយទេ ណាមួយកូនក្ដីខ្លួនមានជីវិភាពក្រីក្រ ដោយមានកូនក្នុងបន្ទុក ព្រមទាំងធានាក្នុងការសងសំណងទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ ។ កូនក្ដីខ្លួនក៏មិនបានរារាំងក្នុងនីតិវិធីនោះ ហើយក៏បានសហការណ៍តាំងពីតុលាការថ្នាក់ក្រោមមកម្ល៉េះ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំតម្កល់សាលដីកាព្រហ្មទណ្ឌទុកជាបានការដដែល ។

-ជនជាប់ចោទឈ្មោ[redacted]គួយ ហៅ ម៉ៅ បានឆ្លើយថា ៖ ខ្លួនឯកភាពតាមការធ្វើសេចក្ដីសន្និដ្ឋានមេធាវីរបស់ខ្លួន ។

-ក្រោយពីបានស្ដាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបាន ស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ
## តុលាការកំពូល

១.យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ១៧៣៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ របស់អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះ តាមមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបាន ។

២.យល់ឃើញថា អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល បានយល់ឃើញថា ការសម្រេចរបស់សាលាឧទ្ធរណ៍ត្បូងឃ្មុំ ដាក់ពន្ធនាគារជនជាប់ចោទ២ឆ្នាំ ក្រោមអប្បរមានៃទោស ពុំត្រឹមត្រូវតាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌឡើយ កម្រិតទោសគឺពី ៥ ទៅ ១០ឆ្នាំ ។ ចំណុចនេះ តុលាការកំពូលពិនិត្យឃើញថា កម្រិតទោសដែលត្រូវអនុវត្តតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ដូចតំណាងមហាអយ្យការបានលើកឡើងពិតមែន ប៉ុន្តែជនជាប់ចោទក៏អាចត្រូវផ្ដល់នូវស្ថានសម្រាលទោស ករណីមានលក្ខខណ្ឌមួយចំនួនដូចមានកំណត់ក្នុងមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ ហើយការដែលសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានផ្ដល់នូវស្ថានសម្រាលដល់ជនជាប់ចោទ មានសំអាងហេតុជាច្រើន ដូចមានក្នុងចំណុចទី៣, ទី៤ និងទី៥ នៃសាលដីការបស់សាលាឧទ្ធរណ៍ត្រឹមត្រូវរួចហើយ ។

៣.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៤៩ ព្រ.ទ ក្រ.IV(រ.ភ) ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដែលសម្រេចសេចក្ដីមកនេះ ត្រឹមត្រូវហើយ ។



Scanned with CamScanner

## ហេតុដូច្នេះ

## សម្រេច

**១.បដិសេធ** បណ្ដឹងសាទុក្ខលេខ ១៧៣៣ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ របស់លោកជំទាវ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ។

**២. តម្កល់** សាលដីកាលេខ ៤៩ ព្រ.ទ ក្រ.IV(វ.ភ) ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ត្បូងឃ្មុំ ទុកជាបានការពេញទាំងមូល ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ ។

| | | |
|---|---|---|
| -ឯកឧត្ដម | [redacted] | ប្រធាន |
| -ឯកឧត្ដម | [redacted] | ចៅក្រម |
| -ឯកឧត្ដម | [redacted] | ចៅក្រម |
| -ឯកឧត្ដម | [redacted] | ចៅក្រម |
| -លោកជំទាវ | [redacted] | ចៅក្រម |
| -លោក | [redacted] | ក្រឡាបញ្ជី |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ថ្ងៃចន្ទ ៦ កើត ខែកត្ដិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ត្រូវនឹងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃចន្ទ ៦ រោច ខែកត្ដិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ត្រូវនឹងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២

**ប្រធានអង្គជំនុំជម្រះ**

[redacted]



Scanned with CamScanner